**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧៨០០ សហវ.ទស

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ៨ ឆ្នាំ ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំគោលការណ៍ថវិកាចំនួន ៨៥.៧៥០,០០ ដុល្លារអាមេរិក សម្រាប់ការបោសសម្អាតមីន និងកាកសំណល់សង្គ្រាម (ជំហានទី ២) នៅទីតាំងគម្រោងការពារទឹកជំនន់ទន្លេកំពង់ត្របែក ខេត្តព្រៃវែង។

**យោង:** លិខិតលេខ ២០១២ ធទឧ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ធ្វើការធានាចំណាយនូវថវិកាបដិភាគរាជរដ្ឋាភិបាល ជាទឹកប្រាក់ចំនួន ៣៤៩.០០០.០០០៛០០ (បីរយសែសិបប្រាំបួនលានរៀលគត់) សម្រាប់ការបោសសម្អាតមីន និងកាកសំណល់សង្គ្រាម (ជំហានទី ២) នៅទីតាំងគម្រោងការពារទឹកជំនន់ទន្លេកំពង់ត្របែក ខេត្តព្រៃវែង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ។ សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន:
- មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកំលាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម
- ឯកសារ-កាលប្បវត្តិ